**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**
**អគ្គនាយកដ្ឋានយោធសេវា**
**នាយកដ្ឋានព័ត៌មាន**
លេខ:....................

## សេក្តីប្រកាសជូនដំណឹង

បន្ទាប់ពីបានបំពេញភាកិច្ចប្រកបដោយជោគជ័យក្នុងបេសកកម្មអន្តរជាតិអាណត្តិមួយឆ្នាំក្រោមឆ័ត្រអង្គការសហប្រជាជាតិ នៅសាធារណរដ្ឋអាហ្វ្រិកកណ្តាល កងវិស្វកម្មលេខ៥៤៩ ចំនួន២១៦នាក់ នឹង ធ្វើ មាតុ ភូមិនិវត្តន៍មកកាន់ព្រះរាជាណាចក្រកម្ពុជាវិញ នៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៦ បន្ទាប់ពីត្រូវបាន ប្តូរ វេនជំនួសដោយ កងវិស្វកម្មលេខ៨៥៩ ចំនួន២១៦នាក់ ដែលត្រូវបានរៀបចំពិធីជូនដំណើរ កាលពីថ្ងៃ ទី០២ ខែវិច្ឆិកា ឆ្នាំ២០១៦ ក្រោមអធិបតីភាព **ឯកឧត្តម នាយឧត្តមសេនីយ៍ ប៉ុល សារឿន អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ** តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា។

ពិធីទទួលដំណើរកងវិស្វកម្មលេខ៥៤៩ ក៏នឹងត្រូវបានរៀបចំឡើងផងដែរក្រោមអធិបតីភាព **ឯកឧត្តម នាយឧត្តមសេនីយ៍ ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ** តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេច អគ្គមហាសេនាបតី តេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងមន្ត្រីសម្របសម្រួលតំណាង អ.ស.ប ប្រចាំនៅកម្ពុជា ភ្ញៀវជាតិ និងអន្តរជាតិជាច្រើនរូបចូលរួមក្នុងពិធីនោះ នៅ ព្រឹកថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៦ វេលាម៉ោង៨:០០ នៅមូលដ្ឋានទ័ពអាកាសពោធិ៍ចិនតុង ៕

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែ វិច្ឆកា ឆ្នាំ ២០១៦

នាយកដ្ឋាន ព័ត៌មាន